ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបន្ទាយមានជ័យ
សំណុំរឿងព្រហ្មទណ្ឌលេខៈ១០៤១
ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៩
ជំនុំជម្រះលេខៈ៨២
ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០

# សាលក្រម

លេខៈ១៩(ង)/២៦៧
ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ

*សាលាដំបូងខេត្តបន្ទាយមានជ័យ*

បានបើកសវនាការជាសាធារណៈនៅសាលជំនុំជម្រះនៃសាលាដំបូងខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង៨ និង៣០នាទីព្រឹក ដោយមានសមាសភាពដូចតទៅៈ

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ ជាប្រធាន
លោក [redacted] ចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ ជាចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តបន្ទាយមានជ័យ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តបន្ទាយមានជ័យ

### មេធាវីការពារសិទ្ធិជនជាប់ចោទ

លោក [redacted]

### មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី

លោក [redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ១០៤១ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទៈ

១/-ឈ្មោះ [redacted] ចាន់ហេង ភេទប្រុស កើតឆ្នាំ១៩៨៧ សញ្ជាតិខ្មែរ ទីកន្លែងកំណើតភូមិ [redacted] ខេត្តកំពង់ចាម ទីលំនៅមុនពេលឃុំខ្លួនភូមិ [redacted] ខេត្តបន្ទាយមានជ័យ ប្រពន្ធឈ្មោះ [redacted] សោភ័ណ មានកូន១នាក់(លែងលះ) ឪពុកឈ្មោះ [redacted] ពែងរិន (រស់) ម្តាយឈ្មោះ [redacted] សុខហៀង (រស់) ជានីតិជន ត្រឹមតែបឋមថ្នាក់ទី៩ ទោសពីមុនគ្មាន។(ឃុំខ្លួនថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៩)

ជាប់ចោទពីបទៈ **ហិង្សាដោយចេតនាស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្តនៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២០



Scanned with CamScanner

ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ។

-ជនរងគ្រោះឈ្មោះ [redacted] អ៊ាង ភេទប្រុស អាយុ៤៧ឆ្នាំ ទីលំនៅបច្ចុប្បន្នភូមិប៉ោយប៉ែត១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ (ស្លាប់)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ហុន ភេទប្រុស កើតឆ្នាំ១៩៧៩ ទីលំនៅបច្ចុប្បន្នភូមិប៉ោយប៉ែត១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

## អង្គហេតុមានដូចតទៅ៖

-កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង១៥ និង៣០នាទី មានករណីហិង្សាស្ថានទម្ងន់ទោស( បណ្តាលអោយមរណៈភាពជនរងគ្រោះ )កើតឡើងនៅចំណុចរង្វង់មូលស្ថិតនៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលបង្កឡើងដោយឈ្មោះ [redacted] **ចាន់ហេង** ភេទប្រុស អាយុ៣២ឆ្នាំ បានយកកាំបិតចិតបន្លែដងខ្មៅចុងស្រួចចាក់ទៅលើជនរងគ្រោះឈ្មោះ [redacted] អ៊ាង ភេទប្រុស អាយុ៤៧ឆ្នាំ បណ្តាលអោយរងរបួសធ្ងន់ ហើយបានស្លាប់នៅមន្ទីរពេទ្យបង្អែកក្រុងប៉ោយប៉ែត។ ក្រោយកើតហេតុរួចកម្លាំងសមត្ថកិច្ចបានកសាងសំណុំរឿងមកអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខៈ ៨៥៧ អ.យ.ខ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

-បានឃើញដីកាដំណោះស្រាយលេខៈ ១៣៣ ពស.ព្រស"ជ"/២០ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ៨៦ ពស.ព្រជ "ក"/២០ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ។

## នាពេលសវនាការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ។

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ។

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ។

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

-ចម្លើយជនជាប់ចោទឈ្មោះ [redacted] ចាន់ហេង បានឆ្លើយសារភាពថា កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ ខ្លួន និងឈ្មោះ [redacted] អ៊ាង ភេទប្រុស អាយុ៤៧ឆ្នាំ នៅរង្វង់មូលស្ថិតនៅភូមិក្បាលស្ពាន សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដោយនាំគ្នាអង្គុយចាំភ្ញៀវដែលបោះក្រាស៊ីឌិតចេញចូល មួយសន្ទុះក្រោយមកឈ្មោះ [redacted] អ៊ាង បានភ្ញៀវចំនួន២នាក់ ខ្លួនបានសុំភ្ញៀវ១នាក់ពីឈ្មោះ [redacted] អ៊ាង តែគាត់មិនព្រមអោយទេ លុះប្រហែលម៉ោង១២ និង១៥នាទី ខ្លួនរកភ្ញៀវបាន២នាក់វិញ ហើយខ្លួនបានអោយភ្ញៀវមួយនាក់ទៅមិត្តភក្តិខ្លួន ពេលនោះខ្លួនបាននិយាយទៅកាន់ឈ្មោះ

[redacted] អ៊ាង ថាបើមានភ្ញៀវចេះចែកគ្នាគ្រាន់បានប្រាក់ទាំងអស់គ្នា ពេលនោះឈ្មោះ [redacted] អ៊ាង ខឹងបានយកផ័ត្រមកវាយលើខ្លួនរហូតដល់បាក់ផ័ត្រ ហើយដេញចាក់មកលើខ្លួនថែមទៀត ត្រូវត្រង់គុមត្រចៀក សៀតថ្ពា ថ្ពាស និងក មានចេញឈាមតិចៗ ហើយត្រូវបានប្រជាពលរដ្ឋនៅទីនោះមកឃាត់ចាប់បំបែក បន្ទាប់មកខ្លួនបានដើរមកយកកាំបិតចិតបន្លែដងខ្មៅចុងស្រួច ហើយដើរត្រឡប់ទៅរកឈ្មោះ [redacted] អ៊ាង វិញក្នុងគោលបំណងកាន់កាំបិតទៅគម្រាមគាត់ តែត្រូវឈ្មោះ [redacted] អ៊ាង ដេញចាក់ខ្លួនម្តងទៀត ទើបខ្លួនយកកាំបិតចិតបន្លែនោះចាក់មកលើឈ្មោះ [redacted] អ៊ាង ហើយខ្លួនបានបោះកាំបិតនោះចោល មិនបានដឹងថាចាក់ត្រូវឈ្មោះ [redacted] អ៊ាង ចំកន្លែងណាទេ រួចខ្លួនបានជិះម៉ូតូចូលប៉ុស្តិ៍ប៉ូលីសដោយខ្លួនឯងប្រាប់ពីរឿងហេតុដែលខ្លួនចាក់ទៅលើឈ្មោះ [redacted] អ៊ាង ក៏ត្រូវប៉ូលីសវាខ្នោះតែម្តង ហើយខ្លួនប្រាប់ថាអ្នកដែលខ្លួនចាក់នោះស្លាប់បាត់ហើយ ចម្លើយសារភាពរបស់ជនជាប់ចោទគឺជាភស្តុតាងមានលក្ខណៈត្រឹមត្រូវតាមច្បាប់អាចឲ្យតុលាការពិចារណាបាន។

-ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ហុន បានឆ្លើយបំភ្លឺថា កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង១២និង៣០នាទី ឈ្មោះ [redacted] ឡាំង ភេទប្រុស ដែលស្នាក់នៅបន្ទប់ជួលក្បែរប្ដីខ្លួនបានទូរស័ព្ទមកប្រាប់ថាប្ដីរបស់ខ្លួនឈ្មោះ [redacted] អ៊ាង ភេទប្រុស អាយុ៤៧ឆ្នាំ ត្រូវបានឈ្មោះ [redacted] ចាន់ហេង ភេទប្រុស អាយុ៣២ឆ្នាំ នៅភូមិមិត្តភាព សង្កាត់ប៉ោយប៉ែត យកកាំបិតចុងស្រួចចិតបន្លែដងខ្មៅចាក់ចំទ្រូងបណ្តាលអោយស្លាប់បាត់បង់ជីវិតហើយ ខ្លួនក៏យកប្ដីទៅធ្វើបុណ្យតាមប្រពៃណី ពេលនេះខ្លួនប្ដឹងសុំទាមទារសំណងជម្ងឺចិត្តចំនួន៣០.០០០(បីម៉ឺន)ដុល្លាអាមេរិក និងសុំឲ្យផ្តន្ទាទោសជនល្មើសតាមច្បាប់ គប្បីតុលាការពិចារណាសម្រេចតាមច្បាប់។

-តាមសេចក្តីចម្លងសំបុត្រមរណភាពលេខ២១ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ បានបញ្ជាក់អោយឃើញថាឈ្មោះ [redacted] អ៊ាង ភេទប្រុស កើតថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៧២ ពិតជាបានទទួលមរណភាព នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ ប្រាកដមែន។

-តាមកំណត់ហេតុទទួលវត្ថុតាង កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៩ នៅដំណាក់កាលអយ្យការ រួមមានផ័ត្របាក់ពណ៌ខៀវចំនួន១ កាំបិតបាក់ដងប្រវែង១៥សង់ទីម៉ែត្រចំនួន១ គឺជាមធ្យោបាយដែលជនរងគ្រោះ និងជនជាប់ចោទយកមកប្រព្រឹត្តបទល្មើស គប្បីតុលាការពិចារណាសម្រេច។

-ក្រោយពីបានបញ្ចប់ការពិភាក្សាដេញដោល, វិភាគលើចម្លើយជនជាប់ចោទ, ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី, របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌, ការស៊ើបអង្កេតនៅដំណាក់កាលអយ្យការ និងការស៊ើបសួរនៅដំណាក់កាលចៅក្រមស៊ើបសួរ គឺជាភស្តុតាងមានភាពស៊ីសង្វាក់គ្នា អាចបញ្ជាក់បានថា កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង១២និង៣០នាទី មានករណីហិង្សាស្ថានទម្ងន់ទោស (បណ្តាលអោយមរណៈភាពជនរងគ្រោះ) កើតឡើងនៅចំណុចរង្វង់មូលស្ថិតនៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលបង្កឡើងដោយឈ្មោះ [redacted] ចាន់ហេង ភេទប្រុស អាយុ៣២ឆ្នាំ បានយកកាំបិតចិតបន្លែដងខ្មៅចុងស្រួចចាក់ទៅលើជនរងគ្រោះឈ្មោះ [redacted] អ៊ាង ភេទប្រុស អាយុ៤៧ឆ្នាំ បណ្តាលអោយរងរបួសធ្ងន់ ហើយបានស្លាប់នៅមន្ទីរពេទ្យបង្អែកក្រុងប៉ោយប៉ែត ប្រាកដមែន បន្ទាប់ពីជនជាប់ចោទបានខឹងនឹងជនរងគ្រោះឈ្មោះ [redacted] អ៊ាង បានយកផ័ត្រវាយទៅលើជនជាប់ចោទត្រូវត្រង់គុមត្រចៀក សៀតថ្ពា និងក បណ្តាលឲ្យចេញឈាមតិចៗ។ ក្រោយកើតហេតុរួចជនជាប់ចោទបានជិះម៉ូតូចូលប៉ុស្តិ៍ប៉ូលីស ហើយប្រាប់ប៉ូលីសពីដំណើររឿងខាងលើ

ក៏ត្រូវកម្លាំងសមត្ថកិច្ចឃាត់ខ្លួន រួចបានកសាងសំណុំរឿងមកអយ្យការអម សាលាដំបូងខេត្តបន្ទាយមានជ័យ។

-អំពើ និងសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ហេង ភេទប្រុស អាយុ៣២ឆ្នាំ គឺជាការប្រព្រឹត្តដោយអចេតនានូវបទល្មើសព្រហ្មទណ្ឌ ដែលមានចែងអោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ។

-ឃើញថាមានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ចាន់ហេង ភេទប្រុស អាយុ៣២ឆ្នាំ ពីបទៈ ហិង្សាដោយចេតនាស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ។

-ឃើញថាជនជាប់ចោទឈ្មោះ [redacted] ចាន់ហេង បានសារភាពនូវទោសកំហុសរបស់ខ្លួន ដែលបានប្រព្រឹត្តលើជនរងគ្រោះដោយគ្មានលាក់លៀមជូនអង្គសវនាការ ហើយបន្ទាប់ពីជនជាប់ចោទបានប្រព្រឹត្តបទល្មើសរួចបានរត់ចូលប៉ុស្តិ៍ប៉ូលីសសារភាពដោយខ្លួនឯង ហើយក៏បានបង្ហាញពីការស្តាយក្រោយផងដែរ ព្រោះថា ជនជាប់ចោទដើមឡើយជាជនរងគ្រោះពីអំពើរបស់ជនរងគ្រោះ តែដោយសារតែការពារខ្លួនលើសពីតុល្យភាពហួសព្រំដែន ធ្វើឲ្យជនជាប់ចោទដែលពីមុនជាជនរងគ្រោះបែជាក្លាយជាជនល្មើសទៅវិញ។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី នាពេលសវនាការ សន្និដ្ឋានថា បន្ទាប់ពីបានស្តាប់ការសួរដេញដោល និងមើលអង្គហេតុ ឃើញថា ជនជាប់ចោទមានចេតនាសម្លាប់ជនរងគ្រោះ ព្រោះថាការវាយតប់គ្នាបានបញ្ចប់ទៅហើយ ហើយជនជាប់ចោទបានយកកូនកាំបិតមកចាក់ជនរងគ្រោះ ហេតុដូច្នេះ ក្នុងនាមខ្លួនជាមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំកែប្រែបទចោទពីហិង្សាដោយចេតនាស្ថានទម្ងន់ទោសដោយសារមរណភាពជនរងគ្រោះ តាមមាត្រា២២៤ នៃក្រមព្រហ្ម ទៅជាបទឃាតកម្មគិតទុកជាមុន តាមមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ ហើយដាក់គុកអស់មួយជីវិត ការសន្និដ្ឋានរបស់មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី គឺពុំបានតភ្ជាប់អង្គហេតុឲ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់ ដោយសារតែជនជាប់ចោទឈ្មោះ [redacted] ចាន់ហេង ខឹងនឹងជនរងគ្រោះឈ្មោះ [redacted] អ៊ាង វាយខ្លួនត្រូវរបួស ទើបទៅយកកូនកាំបិតមកគំរាមជនរងគ្រោះ ហើយត្រូវជនរងគ្រោះយកផ័ត្រវាយទៅលើជនជាប់ចោទជាលើកទីពីរ ទើបជនជាប់ចោទយកកូនកាំបិតចាក់ទៅលើជនរងគ្រោះមួយកូនកាំបិតបណ្តាលឲ្យស្លាប់។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការនាពេលសវនាការ សន្និដ្ឋានពីកស្តុតាងដាក់បន្ទុក និងពិរុទ្ធភាព សុំតម្កល់ការចោទប្រកាន់របស់ខ្លួនមានលក្ខណៈត្រឹមត្រូវតាមច្បាប់។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ នាពេលសវនាការ សន្និដ្ឋានថា បន្ទាប់ពីការសួរដេញដោលឃើញថា កូនក្តីខ្លួនបានសារភាពនូវទោសកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តលើជនរងគ្រោះដោយគ្មានលាក់លៀមជូនអង្គសវនាការបន្ទាប់ពីកូនក្តីខ្លួនបានប្រព្រឹត្តល្មើសរួចហើយបានរត់ចូលប៉ុស្តិ៍ប៉ូលីសដោយខ្លួនឯង ហើយក៏បានបង្ហាញពីការស្តាយក្រោយផងដែរ ព្រោះថា កូនក្តីខ្លួនដើមឡើយជាជនរងគ្រោះពីអំពើរបស់ជនរងគ្រោះ តែដោយសារការពារខ្លួនលើសពីតុល្យភាពហួសព្រំដែន ធ្វើឲ្យកូនក្តីខ្លួនក្លាយជាជនល្មើសទៅវិញ ខ្លួនសូមឲ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនដោយអនុគ្រោះ។

ហេតុដូច្នេះ

**វិនិច្ឆ័យសេចក្តី**

១/-ផ្តន្ទាទោសលើឈ្មោះ [redacted] ចាន់ហេង ភេទប្រុស អាយុ៣២ឆ្នាំ ដាក់ពន្ធនាគារកំណត់៧ (ប្រាំពីរ)ឆ្នាំ ពីបទៈ **ហិង្សាដោយចេតនាស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្ត នៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ។

២/-វត្ថុតាងរួមមានៈ ឆ័ត្របាក់ពណ៌ខៀវចំនួន១ កាំបិតបាក់ដងប្រវែង១៥សង់ទីម៉ែត្រចំនួន១ ត្រូវរឹបអូសបំផ្លាញចោល។

៣/-បង្គាប់អោយឈ្មោះ [redacted] ចាន់ហេង សងសំណងជម្ងឺចិត្តចំនួន៤០.០០០.០០០(សែសិបលាន)រៀល អោយទៅឈ្មោះ [redacted] ចាន់ហុន ទាមទារលើសពីនេះបដិសេធចោល។

៤/-សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង៨ និង៣០នាទីព្រឹក ចំពោះមុខជនជាប់ឈ្មោះ [redacted] ចាន់ហេង និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ហុន ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ ចៅក្រមប្រឹក្សា ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃពុធ ១រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅខេត្តបន្ទាយមានជ័យ,ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]